**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Mar-2012, 08:34
CMS/CFO: Kauv Keoratanak

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ដ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន សុំឲ្យធ្វើការបំភ្លឺពីប្រភេទនៃចំណាត់ថ្នាក់រាល់ឯកសារ ដែលមានលេខសម្គាល់ E3**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ |
|---|---|
| **សហមេធាវីការពារក្តីលោក ខៀវ សំផន** | **អង្គជំនុំជម្រះសាលាដំបូង** |
| លោក គង់ សំអុន | ចៅក្រម និល ណុន |
| លោក Arthur VERCKEN | ចៅក្រម Silvia CARTWRIGHT |
| លោក Jacques VERGES | ចៅក្រម យូរ ឧត្តរា |
| **ជំនួយការ៖** | ចៅក្រម Jean-Ma rc LAVERGNE |
| អ្នកស្រី សេងសុជាតា | ចៅក្រម យ៉ា សុខន |

| | |
|---|---|
| កញ្ញា Marie CAPOTORTO | សហព្រះរាជអាជ្ញា៖ |
| កញ្ញា Shéhérazade BOUARFA | លោកស្រី ជា លាង |
| កញ្ញា Clémence WITT | លោក Andrew CAYLEY |
| កញ្ញា អ៊ូច ស្រីផាត | មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ |
| កញ្ញា Mathilde CHIFFERT | ក្រុមមេធាវីការពារក្តីទាំងអស់ |
| កញ្ញា Samy SALAMON | |

# ជូនចំពោះអង្គជំនុំជម្រះសាលាដំបូង

១. មាត្រា ១.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក/០១/២០០៧/វិ.០៧ ចែងថា លេខសម្គាល់ E3 គឺប្រើសម្រាប់ *"ឯកសារនីមួយៗ បានមកពីសំណុំរឿងស៊ើបអង្កេត ដែលបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដោយយោងតាមវិធាន ៨៧(២) នៃវិធានផ្ទៃក្នុង"*។

២. ចំណែកឯវិធាន ៨៧.២ នៃវិធានផ្ទៃក្នុង ចែងថា*"សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវផ្លងកាត់ការដេញដោល"*។

៣. ផ្ទុយទៅវិញ យើងឃើញថាបច្ចុប្បន្ននេះ មានឯកសារដែលមានលេខសម្គាល់ E3 ជាច្រើនត្រូវបានដាក់នៅក្នុងពេលសវនាការ ប៉ុន្តែឯកសារទាំងនោះមិនត្រូវបានឆ្លងកាត់ការពិភាក្សាដេញដោលនៅក្នុងពេលសវនាការនោះទេ។

៤. ឧទាហរណ៍ដូចជានៅក្នុងសវនាការនាថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា បានបង្ហាញឯកសារចំនួន ១៣ ដល់សាធារណជន។ សវនាការថ្ងៃទី ០៩ កុម្ភៈ នេះ មិនមែនជាពេល ដែលត្រូវដាក់ឯកសារជូនអង្គសវនាការនោះទេ៖

"*ដោយហេតុថា សវនាការនេះពុំពាក់ព័ន្ធនឹងលទ្ធភាពនៃ<u>ការទទួលយកឯកសារណាមួយ ដែលភាគីស្នើសុំដាក់មកអង្គជំនុំជម្រះ</u> ទើបអង្គជំនុំជម្រះមិនបែងចែកពេលវេលាដល់ភាគីដទៃទៀតសម្រាប់ធ្វើការឆ្លើយតបទៅនឹងការបង្ហាញឯកសារទាំងនេះ*"[1]។ (គូសបន្ទាត់ពីក្រោមដោយអ្នកសរសេរ)

៥. ទោះបីជាមានការព្រមាន និងទោះបីជាពុំមានការពិភាក្សាដេញដោលណាមួយត្រូវបានរៀបចំឡើងក៏ដោយ ក៏នៅក្រោយពេលសវនាការ ឯកសារចំនួន ៨ ក្នុងចំណោមឯកសារទាំង ១៣ ដែលបានបង្ហាញ

---

[1] ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារ (ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២) ឯកសារចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E170 កថាខណ្ឌ ៩។

Original FR: 00786750-00786753

និង ដែលពីមុនមិនទាន់ទាំងមានលេខសម្គាល់ E3 ផងនោះ ត្រូវបានគេផ្តល់លេខសម្គាល់ E3[2]។

៦. ឯកសារផ្សេងៗទៀត បានទទួលលេខសម្គាល់ E3 នេះ ដោយមិនទាំងត្រូវបានដាក់នៅក្នុងសវនាការ និង មិនបានធ្វើការពិភាក្សាដេញដោលផង។ ឧទាហរណ៍ ដូចជាឯកសារទាំង ១២៤ ដែលមាននៅក្នុងកំណត់សម្គាល់ជើងទំព័រ នៃដីកាដំណោះស្រាយ ហើយដែលឯកសារទាំងនោះពាក់ព័ន្ធនឹងផ្នែកបរិបទប្រវត្តិសាស្ត្រ[3]។

៧. ដូច្នេះ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន មានហេតុផលគ្រប់គ្រាន់ក្នុងការសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ចង្អុលបង្ហាញឲ្យបានច្បាស់ពីប្រភេទចំណាត់ថ្នាក់នៃឯកសារ ដែលអង្គជំនុំជម្រះបានផ្តល់លេខសម្គាល់ E3។

៨. តើឯកសារទាំងនោះ ជាឯកសារដែលអង្គជំនុំជម្រះសាលាដំបូង គិតថាខ្លួនអាចយកទៅពិភាក្សាសម្រេចដោយមិនចាំបាច់មានការជជែកដេញដោល?

៩. តើឯកសារទាំងនោះ ជាឯកសារដែលអង្គជំនុំជម្រះសាលាដំបូង គិតថានឹងរៀបចំការពិភាក្សាដេញដោលនាពេលក្រោយ ដោយអនុលោមតាមវិធាន ៨៧.២ នៃប្រភេទចំណាត់ថ្នាក់ឯកសារ?

---

[2] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ "សវនាការលើអង្គសេចក្តី - ថ្ងៃទី ២៩" ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E1/41 ទំព័រ ៧ ដល់ទំព័រ ១០។

[3] បញ្ជីឯកសារភ្ជាប់ជាមួយកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E1/16.2។

## យោងតាមសំអាងហេតុខាងលើ

សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង៖

- បញ្ជាក់ឲ្យបានច្បាស់ពីប្រភេទនៃចំណាត់ថ្នាក់ពិតប្រាកដនៃឯកសារទាំងឡាយ ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់លេខសម្គាល់ E3។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Arthur VERCKEN<br>មេធាវី Jacques VERGÈS | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

Original FR: 00786750-00786753